01320582

**Declassified to Public**
**05 May 2021**

D312/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| |
|---|
| **ឯកសារបកប្រែ** |
| **TRANSLATION/TRADUCTION** |
| ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2016, 10:02 |
| CMS/CFO: Ly Bunloung |

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទិននឹងធនធានរបស់ក្រុមមេធាវីការពារក្តី

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
SO Mosseney
Suzana TOMANOVIĆ

**ផ្នែកគាំពារការពារក្តី**
Isaac ENDELEY

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Beini YE

**ផ្នែកធនធានមនុស្ស**
Hamayoon MUBTAKIR

## I- ប្រវត្តិនីតិវិធី

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។

2. នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី យឹម ទិត្យ ("មេធាវីការពារក្តី") បានស្នើសហចៅក្រមស៊ើបអង្កេត សុំបង្គាប់ផ្នែកគាំពារការពារក្តីឲ្យ៖

   ក) បញ្ជាក់ថា មេធាវីការពារក្តីយ៉ាងហោចណាស់ក៏អាចត្រៀមរៀបចំករណីរបស់ខ្លួនស្របតាមខ្ទង់ថវិកាចំនួន ២១០,០០០ ដុល្លារ ដែលបានកំណត់ឲ្យពីដំបូង។

   ខ) ផ្តល់អ្នកជំនាញពិគ្រោះយោបល់ស្ម័គ្រចិត្ត ដើម្បីជួយលោក Neville Sorab មួយរយៈរហូតដល់ពេលគាត់ត្រូវបានចាត់តាំង ឲ្យធ្វើជាសហមេធាវីអន្តរជាតិសម្រាប់ការពារក្តី និង

   គ) ពិចារណាលើសំណើរបស់លោក Sorab ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ សុំដាក់ក្នុងបញ្ជីមេធាវីអន្តរជាតិរបស់ផ្នែកគាំពារការពារក្តី ដោយអនុលោមតាមវិធាន ១១(២)(ឃ)(ii)("សំណើខែ មេសា ឆ្នាំ ២០១៦")[1]។

## II- ពិភាក្សា

### ក) សំណើសុំបញ្ជាក់ថា ថវិកាមេធាវីការពារក្តីមានទឹកប្រាក់ ២១០,០០០ ដុល្លារ

3. ព័ត៌មានខាងក្រោមនេះ ជាព័ត៌មានចាំបាច់ ដើម្បីពិចារណាឲ្យបានត្រឹមត្រូវលើផ្នែកនៃសំណើនេះ៖

   ក) កាលបរិច្ឆេទដែលមេធាវីការពារក្តី បានដឹងពីផ្នែកគាំពារការពារក្តីថា ថវិការបស់ពួកគាត់មានទឹកប្រាក់ ២១០,០០០ ដុល្លារ និង

   ខ) កាលបរិច្ឆេទដែលផ្នែកគាំពារការពារក្តីដឹងថា ថវិកាពិតប្រាកដគឺមានតែ ១៨០, ០០០ ដុល្លារ តែប៉ុណ្ណោះ។

4. នៅពេលយើងទទួលបានព័ត៌មានទាំងនេះសព្វគ្រប់ យើងនឹងពិចារណាលើបញ្ហានេះបន្ថែមទៀត រួមទាំងការពិនិត្យផងដែរ ថាតើយើងមានយុត្តាធិការសម្រេចលើអង្គសេចក្តីបានដែរឬយ៉ាងណា។

---

[1] សំណុំរឿងលេខ 004-D312, *សំណើបន្ទាន់របស់ យឹម ទិត្យ សុំឲ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ផ្នែកគាំពារការការពារក្តីឲ្យផ្តល់មេធាវីការពារក្តី យឹម ទិត្យ នូវធនធានដែលបានលៃទុកពីដំបូង* ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៦ ("សំណើ") ទំព័រទី ១៥។

## ខ) សំណើសុំផ្តល់អ្នកជំនាញពិគ្រោះយោបល់ស្ម័គ្រចិត្ត ដើម្បីជួយលោក Neville Sorab

5. ជាបឋម យើងរម្លឹកថា ជនត្រូវចោទនៅ អ.វ.ត.ក មានសិទ្ធិជាមូលដ្ឋានដើម្បីទទួលបានពេលវេលាគ្រប់គ្រាន់ ក្នុងការត្រៀមរៀបចំការការពារក្តីរបស់ខ្លួន។ ទន្ទឹមនឹងនេះ ពួកគាត់មានសិទ្ធិជាមូលដ្ឋានដើម្បីទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្របមួយ។ សិទ្ធិទាំងនេះ និង សិទ្ធិក្នុងពេលស៊ើបអង្កេតផង តម្រូវឲ្យមេធាវីការពារក្តីទទួលបានធនធានសម្រាប់ការពារក្តី។ កាលណាការស៊ើបអង្កេតកាន់តែយូរ ការចំណាយរបស់ អ.វ.ត.ក និង រដ្ឋដែលម្ចាស់ជំនួយក៏កាន់តែអស់ច្រើន។ ដូច្នេះមានតែវិធានការដែលអាចបង្រួញពេលវេលា ដែលតម្រូវឲ្យមេធាវីការពារក្តីចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការប៉ុណ្ណោះ មានប្រយោជន៍ដល់ទាំង យឹម ទិត្យ អ.វ.ត.ក និង សហគមន៍អន្តរជាតិទាំងមូល។

6. សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ និង សមស្របក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី មានចែងការពារក្នុងមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលកម្ពុជាជាប្រទេសហត្ថលេខីមួយផងដែរ ហើយសិទ្ធិនេះអាចអនុវត្តបានដោយផ្ទាល់នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក[2]។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា មាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ "ផ្តល់នូវសិទ្ធិមានអធិកភាពដែលនឹងធ្វើជាយុត្តិសាស្ត្រសម្រាប់កិច្ចដំណើរការនីតិវិធីជាតិ"[3]។ ដូច្នេះ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ មានឋានានុក្រមខ្ពស់ជាងវិធានផ្ទៃក្នុង និង បញ្ញត្តិរដ្ឋបាល។

7. ដូច្នេះ សំណើរបស់មេធាវីការពារក្តី ដែលមិនធ្វើឲ្យ អ.វ.ត.ក ខាតបង់អ្វី មិនគួរត្រូវបានបដិសេធលើកលែងតែវាមានការរំលោភបំពានវិធានជាក់លាក់ណាមួយ ដែលសំខាន់ស្មើនឹងសិទ្ធិជាមូលដ្ឋានដែលត្រូវគាំទ្រ និង ការពារដោយបញ្ញត្តិពាក់ព័ន្ធនឹងធនធានដែលបានដោយឥតចំណាយប្រាក់។ នៅក្នុងករណីបច្ចុប្បន្ននេះ យើងយល់ឃើញថា រឿងនេះវាមិនមែនដូច្នេះនោះទេ ដោយផ្អែកលើមូលហេតុដូចខាងក្រោម។

---

[2] ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី ចែងយ៉ាងច្បាស់ ដោយបញ្ចូលមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។ សូមមើលផងដែរ វិធាន ២១ ដែលមានចែងអំពីបញ្ញត្តិដែលប្រហាក់ប្រហែលគ្នា។

[3] សំណុំរឿងលេខ 002-D264/2/6, *ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និង សំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ធ្វើឡើងដោយ អៀង ធីរិទ្ធ (D264/1 )* ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ១៣។

i. <u>គម្រោងជំនួយផ្នែកច្បាប់ មិនរារាំងដល់ការបន្តកិច្ចសន្យាអ្នកពិគ្រោះយោបល់ជំនាញរបស់លោក Sorab</u>

8. ទីមួយ យើងយល់ឃើញថា បញ្ញត្តិជាធរមានមិនហាមឃាត់ការបន្តកិច្ចសន្យារបស់ លោក Sorab។

9. គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ចែងថា ថវិកាសម្រាប់ទ្រទ្រង់បុគ្គលិកដូចជាអ្នកពិគ្រោះយោបល់ផ្នែកច្បាប់ អាចប្រើប្រាប់ "*ដើម្បីផ្តល់អ្នកជំនាញរយៈពេលខ្លី សម្រាប់បំពេញកិច្ចការជាក់លាក់មួយចំនួន*"[4]។ គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក នេះមិនបានចែងកំណត់ថេរវេលានៃពាក្យ"រយៈពេលខ្លី"នេះទេ។ ដើម្បីឱ្យស្របតាមវិធាន ២១ គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ត្រូវតែបកស្រាយក្នុងន័យការពារប្រយោជន៍ យឹម ទិត្យ។

10. ការប៉ុនប៉ងណាមួយ ក្នុងការកំណត់ថេរវេលានៃពាក្យ"រយៈពេលខ្លី" នៅក្នុងបរិបទនៃគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក មិនត្រូវដកចេញពីការពិចារណាលើរយៈពេលស៊ើបអង្កេតទាំងមូល និង កាលបរិច្ឆេទនៃការតែងតាំងសហមេធាវីសម្រាប់ យឹម ទិត្យ។ ការស៊ើបអង្កេតនៃសំណុំរឿង ០០៤ ចាប់ផ្តើមធ្វើនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ជាមួយនឹងការដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី ដែលដាក់ដោយសហព្រះរាជអាជ្ញាស្តីទី[5] និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិមុន បានទទួលស្គាល់សហមេធាវី យឹម ទិត្យ ជាលើកដំបូងនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤[6]។ លោក Sorab ធ្វើជាអ្នកពិគ្រោះយោបល់ជំនាញអស់រយៈពេលបីខែកន្លះ ចាប់ពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦។ ដោយពិចារណាលើតួលេខនេះ និងពិចារណាបន្ថែមលើទំហំនៃការស៊ើបអង្កេតប្រឆាំង យឹម ទិត្យ និង វិធាន ២១ យើងជឿជាក់ថា ការបន្តកិច្ចសន្យាឱ្យលោក Sorab នឹងរំលោភលក្ខខណ្ឌ"រយៈពេលខ្លី" ដូចមានចែងក្នុងគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ពាក់ព័ន្ធនឹងការអ្នកពិគ្រោះយោបល់ជំនាញនោះទេ។

11. មិនតែប៉ុណ្ណោះ ផ្នែកទី ២.២ នៃគោលការណែនាំផ្នែករដ្ឋបាលស្តីពីការតែងតាំងបណ្តោះអាសន្នរបស់អង្គការសហប្រជាតិ ដែលស្រដៀងគ្នានឹងគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ដាក់កំហិតការតែងតាំងបុគ្គលិកបណ្តោះអាសន្ន ក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ មកត្រឹម"រយៈពេល

---

[4] គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ចុះខែ ធ្នូ ឆ្នាំ ២០១៤ ផ្នែក ជ(១)។

[5] សំណុំរឿងលេខ 004-D1/1, *សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ៣* ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[6] សំណុំរឿងលេខ 004-D122/9/6, *ដីកាសម្រេចស្តីពីការទទួលស្គាល់សហមេធាវីសម្រាប់ជនសង្ស័យ យឹម ទិត្យ* ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤។

ខ្លី"មួយ[7]។ អនុលោមតាមគោលការណ៍ណែនាំផ្នែករដ្ឋបាលនេះ ការតែងតាំង"រយៈពេលខ្លី" អាចមានរយៈពេលរហូតដល់ ៣៦៤ ថ្ងៃ និង អាចបន្តបានរហូតដល់ ៧២៩ ថ្ងៃក្នុងកាលៈទេសៈពិសេស[8]។ ដូច្នេះ លោក Sorab ធ្វើការជាអ្នកពិគ្រោះយោបល់ជំនាញ បានតិចថ្ងៃរយៈពេលដែលចាត់ទុកថាជា "រយៈពេលខ្លី" ពាក់ព័ន្ធនឹងបុគ្គលិកបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ។

12. ក្នុងការអនុវត្តគោលការណ៍ភាពស្មើគ្នានៃកម្លាំង យើងរកមិនឃើញមូលហេតុណាមួយ ដែលមេធាវីការពារក្ដី ត្រូវដាក់ឲ្យស្ថិតក្នុងស្ថានភាពចាញ់ប្រៀបភាគីដទៃទៀត ក្នុងកិច្ចដំណើរការនីតិវិធីនោះទេ។ ឧទាហរណ៍ សហព្រះរាជអាជ្ញាអាចទទួលបានសេវាពីបុគ្គលិកបណ្ដោះអាសន្នរហូតដល់ ៣៦៤ ថ្ងៃ ឬ ៧២៩ ថ្ងៃក៏មាន។ ដូច្នេះ យើងយល់ឃើញថា គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ត្រូវតែបកស្រាយក្នុងន័យអនុញ្ញាតឲ្យលោក Sorab បន្តកិច្ចការជាអ្នកពិគ្រោះយោបល់ជំនាញយ៉ាងហោចក៏បាន ៣៦៤ ថ្ងៃ រួមទាំងលទ្ធភាពក្នុងការបន្តកិច្ចសន្យានេះតទៅទៀត ប្រសិនបើកាលៈទេសៈពិសេសតម្រូវ។

13. លើសពីនេះទៅទៀត ដូចយើងធ្លាប់បញ្ជាក់ម្ដងហើយក្នុងដីកាសម្រេចក្នុងករណីនេះ គ្មានបញ្ញត្តិជាធរមានណាមួយ ហាមមិនឲ្យអ្នកពិគ្រោះយោបល់ជំនាញបំពេញការងារពីចម្ងាយបាននោះទេ។ មានតែសហមេធាវីប៉ុណ្ណោះ ដែលស័ក្ដិសមជាអ្នកសម្រេច ក្នុងការដាក់ និង គ្រប់គ្រងធនធានរបស់ពួកគាត់របៀបណា ដើម្បីធានាឲ្យបាននូវការធ្វើជាតំណាងកូនក្ដីរបស់ពួកគាត់ឲ្យបានពេញលេញ[9]។ តាមដែលយើងយល់ពីសំណើរបស់មេធាវីការពារក្ដី ការិយាល័យសហចៅក្រមស៊ើបអង្កេត និង ក្រុមមេធាវីការពារក្ដីផ្សេងទៀត ធ្លាប់ជួលអ្នកពិគ្រោះយោបល់ ដែលបំពេញការងាររបស់ពួកគាត់ពីចម្ងាយដូច្នេះដែរ។ ប្រសិនបើសហមេធាវីយល់ឃើញថាលោក Sorab អាចជួយដល់ការងាររបស់មេធាវីការពារក្ដី តាមរយៈការបំពេញកិច្ចការរបស់គាត់ពីចម្ងាយ សំណើរបស់ពួកគាត់ត្រូវតែទទួលបានការយល់ព្រម។

14. យើងយល់ថា បញ្ហាអ្នកពិគ្រោះយោបល់ជំនាញ ដែលបំពេញការងារពីចម្ងាយនេះ ត្រូវបានដោះស្រាយហើយ។ ជាប្រយោជន៍ដល់យុត្តិធម៌ ភាពឆាប់រហ័ស និង ការសន្សំសំចៃសម្រាប់តុលាការយើង រំពឹងថា បញ្ហានេះនឹងមិនត្រូវលើកឡើងជាថ្មីទៀតទេ ពោលគឺពាក់ព័ន្ធនឹងការជ្រើសរើស

---

[7] ST/AI/2010/4/REV.1, ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១។

[8] ដូចខាងលើ ផ្នែកទី ២.៥, ២.៧ និង ១៤។

[9] សំណុំរឿងលេខ 004-D304/4, *ដីកាសម្រេចបន្ថែមលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យផ្នែកគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម* ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ១៤-១៦។

បុគ្គលិក ដែលដាក់ស្នើឡើងដោយសហមេធាវី សម្រាប់ជនត្រូវចោទក្នុងសំណុំរឿង ០០៣ និង ០០៤។

ii. គម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក មិនប៉ះពាល់ដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ ដូចមានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

15. ទោះបីជាបញ្ញត្តិរដ្ឋបាលជាធរមាន ហាមមិនឲ្យបន្តកិច្ចសន្យារបស់លោក Sorab ដោយពិចារណាលើឋានានុក្រមកំពូលនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលមានអានុភាពលើបញ្ញត្តិរដ្ឋបាល យើងមានកាតព្វកិច្ចពិចារណាប្រើអំណាចឥស្សរចិត្តរបស់យើង ដើម្បីបង្ការកុំឲ្យមានរំលោភសិទ្ធិរបស់ជនត្រូវចោទ។

16. ទោះជាយើងសន្និដ្ឋានថា គ្មានប្រការណាមួយដែលហាមឃាត់ការបន្តកិច្ចសន្យារបស់លោក Sorab ក៏ដោយ ក៏មិនចាំបាច់អនុវត្តវិធានការបែបនេះ ក្នុងករណីដែលកំពុងស្ថិតក្នុងដែនាពេលឥឡូវនេះទេ។

iii. សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងការបន្តកិច្ចសន្យារបស់លោក Sorab ជាអ្នកពិគ្រោះយោបល់ជំនាញ

17. ដូចបានរៀបរាប់ខាងលើ យើងយល់ឃើញថា ការបដិសេធក្នុងការបន្តកិច្ចសន្យារបស់លោក Sorab ដែលជាអ្នកពិគ្រោះយោបល់ជំនាញដោយស្ម័គ្រចិត្ត គឺមិនសមហេតុផល និង ផ្ទុយទៅនឹងការចង់បានការបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ឲ្យបានឆាប់រហ័ស។ ដូច្នេះ យើងមិនបង្គាប់ឲ្យផ្នែកគាំពារការពារក្តី បន្តការតែងតាំងលោក Sorab ក្នុងពេលឥឡូវទេ គឺចាំទាល់តែគាត់បំពេញចប់សព្វគ្រប់នូវកិច្ចការ ដែលផ្នែកគាំពារការពារក្តីបានដាក់ឲ្យគាត់ធ្វើសិន។ ប៉ុន្តែ មុននឹងឈានទៅចេញសេចក្តីបង្គាប់នេះ យើងចង់ផ្តល់ឱកាសឲ្យប្រធានផ្នែកធនធានមនុស្ស បង្ហាញហេតុផលគួរឲ្យជឿជាក់ណាមួយ ដែលមិនអនុញ្ញាតឲ្យមេធាវីការពារក្តី និង យឹម ទិត្យ ក្នុងការទទួលបានផលប្រយោជន៍ពីជំនួយរបស់អ្នកពិគ្រោះយោបល់ជំនាញដែលមានគុណវុឌ្ឍិ និង បទពិសោធន៍ និង ជួយដោយស្ម័គ្រចិត្ត ដោយ អ.វ.ត.ក មិនត្រូវចំណាយអ្វីសោះនេះ។

**គ) សំណើសុំឲ្យពិចារណាដាក់ពាក្យសុំរបស់លោក Sorab ចុះខែ មេសា ឆ្នាំ ២០១៦ ទៅក្នុងបញ្ជីឈ្មោះសហមេធាវីអន្តរជាតិរបស់ផ្នែកគាំពារការការពារក្តី អនុលោមតាមវិធាន ១១(២)(ឃ)(ii)**

18. ដូចដែលយើងបានបញ្ជាក់នៅក្នុងដីកាសម្រេចមួយទៀតក្នុងករណីនេះ អំណាចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការពិនិត្យមើលសេចក្ដីសម្រេចផ្នែករដ្ឋបាល មានលក្ខណៈកំហិតត្រឹមតែករណីដែលសេចក្ដីសម្រេចទាំងនោះ អាចប៉ះពាល់ដល់សិទ្ធិជំនុំជម្រះរបស់ជនត្រូវចោទប៉ុណ្ណោះ[10]។

19. អនុលោមតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និង វិធាន ២១ ជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌនៅ អ.វ.ត.ក ត្រូវមានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានមេធាវីការពារក្ដី។ វិធាន ២២ ចែងថា ជនណាដែលត្រូវមានសិទ្ធិមានមេធាវីដោយអនុលោមតាមវិធាននេះ ត្រូវមានសិទ្ធិទទួលបានមេធាវីជាតិ ឬ មេធាវីអន្តរជាតិសហការគ្នាជាមួយមេធាវីជាតិ។ បច្ចុប្បន្ននេះ យឹម ទិត្យ មានមេធាវីពីរនាក់តំណាង ពោលគឺមានមេធាវីជាតិមួយនាក់ និង មេធាវីអន្តរជាតិមួយនាក់។ ដូច្នេះ ការដែលផ្នែកគាំពារការការពារក្ដី បដិសេធក្នុងការតែងតាំងលោក Sorab មិនប៉ះពាល់ដល់សិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបានតំណាងផ្នែកច្បាប់នោះទេ។

20. ក្នុងកាលៈទេសៈទាំងអស់នេះ និង ដោយយោងទៅលើអង្គសេចក្ដីនៃសំណើសុំដំណោះស្រាយរបស់មេធាវីការពារក្ដី យើងយល់ឃើញថា បញ្ហានេះមិនស្ថិតក្រោមអំណាចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបង្គាប់ឲ្យផ្នែកគាំពារការពារក្ដី ដើម្បីពិចារណាតែងតាំងលោក Sorab ជាសហមេធាវី ដូចបានស្នើឡើងដោយមេធាវីការពារក្ដីនោះទេ។ ម្យ៉ាងទៀត បញ្ហានេះហួសពីសមត្ថកិច្ចគោលរបស់ខ្លួន ពាក់ព័ន្ធនឹងការទទួលយកមេធាវី។ ទោះជាយ៉ាងនេះក្ដី ដំណោះស្រាយសមស្រប ពាក់ព័ន្ធនឹងការជំទាស់ទៅនឹងការបដិសេធរបស់ផ្នែកគាំពារការការពារក្ដី គឺប្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

21. ដូច្នេះ សំណើសុំឲ្យផ្នែកគាំពារការការពារក្ដីពិចារណាពាក្យសុំចុះខែ មេសា ឆ្នាំ ២០១៦ នេះមិនអាចទទួលយកបានទេ។

22. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយ។

**តាមសម្អាងហេតុខាងលើ យើង៖**

23. **ស្នើឲ្យ** មេធាវីការពារក្ដី និង ផ្នែកគាំពារការការពារក្ដី ជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេតដោយមានភ័ស្ដុតាងសមស្រប ឲ្យបានត្រឹមថ្ងៃ សុក្រ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ពាក់ព័ន្ធនឹង៖

[10] ដូចខាងលើ កថាខណ្ឌ ១៨។

ក) កាលបរិច្ឆេទ និង មធ្យោបាយដែលមេធាវីការពារក្តី បានដឹងពីផ្នែកគាំពារការពារក្តីថា ថវិការបស់ពួកគាត់មានទឹកប្រាក់ ២១០,000 ដុល្លា និង

ខ) កាលបរិច្ឆេទដែលផ្នែកគាំពារការពារក្តីដឹងថា ថវិកាពិតប្រាកដមានត្រឹមតែ ១៨០,000 ដុល្លា។

24. **អញ្ជើញ** ប្រធានផ្នែកធនធានមនុស្ស ឲ្យជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ប្រសិនបើគាត់ចង់ធ្វើដូច្នេះ ឲ្យបានត្រឹមថ្ងៃ សុក្រ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ពាក់ព័ន្ធនឹងមូលហេតុដែលគួរឲ្យជឿជាក់ណាមួយដែលប្រឆាំងនឹងការបន្តកិច្ចសន្យារបស់លោក Neville Sorab ជាអ្នកពិគ្រោះយោបល់ជំនាញស្ម័គ្រចិត្ត សម្រាប់ក្រុមមេធាវីការពារក្តី។

25. **បដិសេធ** សំណើរបស់មេធាវីការពារក្តី ដែលសុំឲ្យផ្នែកគាំពារការការពារក្តី ពិចារណាពាក្យសុំចុះខែ មេសា ឆ្នាំ ២០១៦។

26. **នៅបន្តពិនិត្យ** សំណើនោះ។

ភ្នំពេញ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**

Original EN: 01249190-01249194